**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ជូនចំពោះ**

**ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោកអគ្គកុងស៊ុល**

**មន្ត្រីការទូត និងបុគ្គលិកនៃស្ថានតំណាងកម្ពុជាទាំងអស់នៅក្រៅប្រទេស**

ក្នុងឱកាសប្រកបដោយសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ខ្ញុំសូមជូននូវសព្ទសាធុការពរជ័យ សិរីសួស្តី មហាប្រសើរ ចំពោះឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោកអគ្គកុងស៊ុល មន្ត្រីការទូត និងបុគ្គលិកគ្រប់ជាន់ថ្នាក់ ដែលកំពុងបំរើការនៅតាមស្ថានតំណាងកម្ពុជាទាំងអស់នៅក្រៅប្រទេស សូមជួបតែសេចក្តីសុខ សុភមង្គល និងមានសុខភាពល្អបរិបូណ៌ នៅក្នុងឆ្នាំថ្មីដែលនឹងឈានមកដល់នាពេលខាងមុខនេះ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្នុងឆ្នាំថ្មីនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ នឹងបន្តខិតខំប្រឹងប្រែងបំពេញភារកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីព្យាយាម និងទទួលខុសត្រូវខ្ពស់ ឈរលើមូលដ្ឋាននៃការកំណត់ទិសដៅការងារទាំង៥របស់ក្រសួង និងរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានទៅរកភាពជោគជ័យត្រចះត្រចង់។ នៅក្នុងពិភពលោកដែលមានការប្រែប្រួលនាពេលបច្ចុប្បន្ននេះ ការប្តេជ្ញាចិត្តប្រកបដោយឆន្ទៈមោះមុត និងស្មោះត្រង់របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ក្នុងកិច្ចការបំរើជាតិមាតុភូមិ ជាកត្តាចាំបាច់បំផុត ដើម្បីចូលរួមថែរក្សាសេចក្តីសុខសន្តិភាព ស្ថិរភាពនយោបាយ ការពារអធិបតេយ្យភាពជាតិដែលជាមូលដ្ឋានគ្រឹះសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិលើ គ្រប់វិស័យ ជូនមាតុភូមិអង្គរជាទីស្នេហារបស់យើង។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយប្រោះព្រំប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ ជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងក្រុមគ្រួសារ សូមប្រកបតែសេចក្តីសុខចំរុងចំរើន និងជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ពុធ ៦ កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៩

**ប្រាក់ សុខុន**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh